**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

លេខ០២៨/០៨ របក.អគគ

**របាយការណ៍ ស្តីពី សកម្មភាពការងារប្រចាំខែ សីហា ឆ្នាំ ២០០៨**
**របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត**

ក្នុងខែ សីហា ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ក. ការងាររដ្ឋបាល**

-ផ្ញើដីកាអមកំណត់ហេតុសិក្ខាសាលាផ្សព្វផ្សាយគេហទំព័រស្តីពីប្រភពធនធាន នៃការបណ្តុះ-បណ្តាល សិទ្ធិមនុស្ស នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨

-ផ្ញើលិខិតជូនឯកឧត្តមទេសរដ្ឋមន្ត្រី ដើម្បីចូលរួមសិក្ខាសាលា ស្តីពីការរៀបចំគម្រោងស្នើសុំហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការពីរដ្ឋាភិបាលជប៉ុន ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា/គណៈកម្មា-ធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នឹងរៀបចំធ្វើនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៨

-ផ្ញើលិខិតស្នើជួយផ្តល់អនុសាសន៍លើសេចក្តីព្រាងសៀវភៅស្តីពី "មគ្គុទ្ទេសក៍នៃការធ្វើផែនការក្នុង វិស័យយុត្តិធម៌" ជូនប្រធាននាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨។

-បានទទួលលិខិតអញ្ជើញ ចូលរួមកិច្ចប្រជុំស្តីពីដំណើរការ និងប្រសិទ្ធភាពរបស់លេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសចម្រុះ (Performance and Effectiveness of TWGs Secretariat) ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨

-បានទទួលលិខិតស្នើបញ្ជូនឈ្មោះមន្ត្រីរាជការ ដែលត្រូវទទួលគ្រឿងឥស្សរិយយសសម្រាប់ឆ្នាំ២០០៨ ពីទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៨

-បានទទួលដីកាអមពីរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ស្តីពីលិខិតអញ្ជើញចៅក្រមកម្មសិក្សា ចំនួន៧រូប ចូលរួមវគ្គបណ្តុះបណ្តាលគរុកោសល្យមុខវិជ្ជារដ្ឋប្បវេណី នៅប្រទេសជប៉ុន ដែលនឹងប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី៦ ដល់ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨។

-បានទទួលលិខិតស្នើសុំអញ្ជើញចូលរួលវគ្គបណ្តុះបណ្តាលបន្ត ស្តីពី "សេចក្តីព្រាងក្រមព្រហ្មទណ្ឌ និងច្បាប់ លក្ខន្តិកៈចៅក្រម ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទល្មើសព្រហ្មទណ្ឌបណ្តាលមកពីទំនាស់ដីធ្លី" នៅរាជបណ្ឌិតសភា វិជ្ជាជីវៈតុលាការ។

**ខ. ការងារកំណែទម្រង់**

-ប្រជុំអង្គភាពគ្រប់គ្រងគម្រោង (PMU) ស្តីពីយុទ្ធសាស្ត្រទំនាក់ទំនង (Communication Strategy) សម្រាប់ PMU

-ប្រជុំក្រុមការងារសហប្រតិបត្តិការជាមួយ GTZ នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៨ ស្តីពីការកំណត់ភារកិច្ច និងអ្នកទទួលខុសត្រូវលើសកម្មភាពទាំងបី នៃគម្រោងផ្អែកតាមសេចក្តីសម្រេចរបស់អង្គភាពគ្រប់គ្រងគម្រោង ក្រោមអធិបតីភាពឯកឧត្តម សួង លាងហៃ

-ប្រជុំក្រុមការងារជាមួយលោក ពនេ អ្នកជំនាញការ CCJAPIII ដើម្បីរៀបចំ កម្មវិធីនៃការចូលរួមរបស់សង្គមស៊ីវិល ក្នុងកំណែទម្រង់ច្បាប់ និងតុលាការ និងកម្មវិធីតាមដានការត្រួតពិនិត្យ សកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការរបស់ស្ថាប័នអនុវត្តផ្សេងៗ

-ចូលរួមជាវាគ្មិនក្នុងកម្មវិធី មាគ៌ានៃច្បាប់របស់វិទ្យុ ១០២ ធំ ស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដោយលោក ឃ្លោក ដារ៉ា តំណាងអង្គភាពគ្រប់គ្រងគម្រោង

-ប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ ដើម្បីពិភាក្សាលើចំលើយចំពោះសំណួររបស់តុលាការគំរូ នៅ ថ្ងៃ ទី០៨ ខែសីហា ឆ្នាំ២០០៨

-ប្រជុំជាមួយតំណាង GTZ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ស្តីពីគម្រោងដែលគាំទ្រដោយ GTZ ក្រោមអធិបតីភាពឯកឧត្តម ស៊ុយ ម៉ុងលាង

-ប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ ដើម្បីពិភាក្សាលើចំលើយចំពោះសំណួររបស់តុលាការគំរូ នៅ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨

-ប្រជុំក្រុមការងារសហប្រតិបត្តិការជាមួយ GTZ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ស្តីពីលទ្ធភាពនៃការរៀបចំទិន្នន័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិក្នុងគេហទំព័រ អង្គភាពគ្រប់គ្រងគម្រោង

-បញ្ចប់ការវិភាគបឋមលើសំណួរចំលើយតុលាការគំរូទាំងបួន (សាលាដំបូងខេត្តបន្ទាយ-មានជ័យ សាលាដំបូងខេត្តកណ្តាល សាលាដំបូងខេត្តកំពង់ចាម និងសាលាដំបូងក្រុងភ្នំពេញ) នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨

-ប្រជុំក្រុមការងារ GTZ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨ ពិនិត្យលក្ខខណ្ឌយោងនៃគម្រោងបង្កើត អំប៊ុដស្មាន់

-ប្រជុំជាមួយអ្នកជំនាញការ GTZ ដើម្បីពិភាក្សាការអនុវត្តការសិក្សាវាយតម្លៃជាបឋមលើសកម្មភាពពាក់ព័ន្ធដល់អំប៊ុដស្មាន់ ដែលកំពុងអនុវត្តនៅកម្ពុជា

-ប្រជុំអង្គភាពគ្រប់គ្រងគម្រោង នៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០៨ ដើម្បីលើកយោបល់សម្រាប់សន្និសីទថ្នាក់ជាតិ (National Conference) ដែលនឹងរៀបចំដោយ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

**គ. ផ្សេងៗ**

-ទទួលជួបក្រុមការងារ IFC ស្វែងយល់ពីការអនុវត្តច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៨

-ចូលជួបលេខាធិការដ្ឋាន កែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចសុំយោបល់ លើការរៀបចំសៀវភៅផែនការរបស់អង្គភាពគ្រប់គ្រងគម្រោង នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៨

-ទទួលជួប និស្សិតកម្មសិក្សាមកពីប្រទេសជប៉ុន ស្វែងយល់ពីការកែទម្រង់ច្បាប់ និង តុលាការ នៅព្រះរាជាណាចក្រកម្ពុជា

-ចូលរួមប្រជុំអន្តរក្រសួង ពិភាក្សាលើសេចក្តីព្រាងគោលនយោបាយ យុទ្ធសាស្ត្រ និង ផែនការសកម្មភាព សម្រាប់បបនីយជីវមណ្ឌលបឹងទន្លេសាប ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨

-ចូលរួមប្រជុំអន្តរក្រសួង ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង កម្មសិទ្ធិបញ្ញា ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨

-ចូលរួមប្រជុំអន្តរក្រសួង ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតសញ្ញារបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១៩ និងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨

-ចូលរួមប្រជុំអន្តរក្រសួង ពិភាក្សាលើសេចក្តីព្រាងគោលនយោបាយជាតិទេសចរណ៍ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨។

**២-សន្និដ្ឋាន**

ក្នុងខែ សីហា ឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ ទន្ទឹងនឹងការបន្តសកម្មភាពលើគម្រោងដែលមានស្រាប់ដូចជាតុលាការគំរូ និងប្រព័ន្ធសូចនាករជាដើម កំពុងតែប្រឹងប្រែងធ្វើឱ្យចេញជារូបរាងនូវគម្រោងសហប្រតិបត្តិការថ្មីមួយទៀត ជាមួយកម្មវិធីអង្គការ GTZ។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

-បន្តអនុវត្តគម្រោងតុលាការគំរូ ជាពិសេសធ្វើសម្ព័ន្ធចម្លើយ និងសំណួរ និងផែនការការងារសម្រាប់តុលាការក្រុងភ្នំពេញ តុលាការខេត្តកំពង់ចាម តុលាការខេត្តកណ្តាល និងតុលាការខេត្តបន្ទាយមានជ័យ

-បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដាន

-បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ

-រៀបចំធ្វើការពិភាក្សាជាមួយ DANIDA ស្តីពីកិច្ចសហការរវាង DANIDA+ DIHR និងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សម្រាប់ឆ្នាំ២០០៩

-ទំនាក់ទំនងជាមួយ CCJAPIII ដើម្បីស្វែងរកជំនួយ ដើម្បីយកមករៀបចំN សិក្ខាសាលាផ្លាស់ប្តូរយោបល់ជាមួយនឹងស្ថាប័នរដ្ឋ និងសង្គមស៊ីវិលបន្តទៀត។

រាជធានី ភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨

អ្នកធ្វើរបាយការណ៍

ហ៊្សឹង សុកុល

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង